អង្គការរ៉ឺម៉កកង់បី
សម្រាប់កុមារ R4C




សូមស្កេនQR Code

គំនូរជីវចល    ធនធានបង្រៀន

Written by TukTuk    Illustrated by Choven Hen



អង្គការរ៉ឺម៉កកង់បី
សម្រាប់កុមារ R4C

ថ្ងៃនេះ រតនានិងមករាសប្បាយចិត្តខ្លាំងណាស់ ដោយសារវ៉ាកងតូចទើបចាប់ផ្ដើម។
ថ្ងៃចូលឆ្នាំប្រពៃណីខ្មែរជិតមកដល់ហើយ ដូចនេះម្នាក់ៗរវល់ណាស់ ព្រោះមានរបស់របរច្រើនត្រូវរៀបចំ។



នៅថ្ងៃចន្ទ រតនានិងមករាបានទៅទិញខោអាវនៅផ្សារជាមួយម្ដាយគាត់។
រតនាស្រឡាញ់រ៉ូបពណ៌ខៀវដ៏ស្រស់ស្អាតមួយ តែពេលនាងលទៅ រ៉ូបនោះបែរជាតូចពេក។
ដូច្នេះនាងក៏សាកល្បងរ៉ូបពណ៌បៃតងវិញ តែវាបែរជាធំពេកទៅវិញ។
ចុងក្រោយនាងក៏សាករ៉ូបពណ៌លឿងមួយដែលត្រូវនឹងខ្លួននាងល្មមតែម្ដង។
ឯមករាវិញបានទិញខោពណ៌ក្រហមនិងអាវយឺតឆ្នូតមួយផងដែរ។

អង្គការរ៉ឺម៉កកង់បី
សម្រាប់កុមារ R4C




នៅថ្ងៃអង្គារ មានសំឡេងស៊ីប្លេនៅក្រៅផ្ទះរបស់ក្មេងៗ។
ម្តាយរបស់ក្មេងទាំងពីរនិយាយ « ម៉ោះ! ថ្ងៃនេះយើងត្រូវទិញអីវ៉ាន់ច្រើនណាស់ »។ លោកគ្រូសុខកំពុងចាំពួកគេនៅលើរ៉ឺម៉កកង់បី។
សាកទាយមើលនរណាគេជាអ្នកបើករ៉ឺម៉កកង់បី? គឺយ៉េកនោះឯង! រតនានិងមករាសប្បាយចិត្តណាស់ដែលបានជួបយ៉េកម្តងទៀត។
លោកគ្រូសុខបានណែនាំយ៉េកឱ្យម្តាយក្មេងទាំងពីរបានស្គាល់។
រតនាសួរ « តើខេទីនៅឯណា? »
យ៉េកក៏ឆ្លើយ « មកពីមនុស្សច្រើនពេក ប្រហែលជិះមិនអស់ទេ ដូច្នេះនាងក៏ចាំនៅផ្ទះទៅ »។









ពេលទៅដល់ផ្សារ ពួកគេបានទិញភ្លើងលំអ ទាននិងធូបជាច្រើន។ យ៉េកសួរ « ទិញរបស់ទាំងនេះសម្រាប់ធ្វើអីហ្នឹង? » មករាឆ្លើយ « សម្រាប់អបអរថ្ងៃចូលឆ្នាំខ្មែរហ្នឹងណា »។ « ចុះស្បោងធំនោះវិញដាក់អីហ្នឹង? » តែលោកគ្រូសុខមិនឆ្លើយទេ បានត្រឹមញញឹម។ ម្ដាយពួកគេក៏សួរទៅយ៉េក « យ៉េក! ចុះថ្ងៃបុណ្យចូលឆ្នាំខ្មែរនេះប្រុងធ្វើអ្វីដែរ? »
យ៉េកឆ្លើយ « អត់មានគម្រោងថានឹងធ្វើអីផង »។ ម្ដាយពួកគេនិយាយទៀត « អីចឹងអ្នកនិងខេទីអាចមកលេងពួកយើងបាន ហើយសឹមទៅវត្តទាំងអស់គ្នាតែម្ដង »។ យ៉េកក៏ឆ្លើយ « បើអីចឹងមែនប្រសើរណាស់! អរគុណមីងច្រើនមែនទែន។ ចាំខ្ញុំដឹកអ្នកទាំងអស់គ្នាទៅតែម្ដង »។ ឮដូចនេះ ក្មេងៗក៏ស្រែកហោដោយក្ដីសប្បាយរីករាយ។

អង្គការរ៉ឺម៉កកង់បី
សម្រាប់កុមារ R4C



នៅថ្ងៃពុធ រតនានិងមករាជួយម្ដាយពួកគេសម្អាតផ្ទះ ខណៈពេលដែលគាត់នៅរវល់រៀបចំចម្អិនចំណីអាហារ។



រីឯថ្ងៃព្រហស្បតិ៍វិញ យ៉េកនិងខេទីបានជិះរ៉ឺម៉កកង់បីមកដឹកអ្នកទាំងអស់គ្នាទៅផ្សារម្ដងទៀត។



ម្តងនេះ ពួកគាត់ទិញតែផ្លែឈើប៉ុណ្ណោះ មានផ្លែម្នាស់ ក្រូច ស្វាយ ល្ហុង ចេកនិងផ្លែខ្នុរ។
យប់នោះ រតនានិងមករាសប្បាយចិត្តខ្លាំងសឹងតែដេកមិនលក់។

អង្គការរ៉ឺម៉កកង់បី
សម្រាប់កុមារ R4C



ជាចុងក្រោយ ថ្ងៃសុក្រដែលជាថ្ងៃចូលឆ្នាំទីមួយបានមកដល់។ យ៉េក និងខេទី នាំគ្នាជិះរ៉ឺម៉កកង់បីមកជាមួយគ្នា ឯលោកគ្រូសុខបានដើរមកជួបជុំគ្នានៅផ្ទះរតនា និងមករា។

ខេទីលាន់មាត់៖ អូ! តុបតែងបានស្អាតខ្លាំងណាស់ថ្ងៃនេះ! លោកគ្រូសុខក៏ប្រាប់យ៉េក និងខេទីថា ថ្ងៃទីមួយនៃបុណ្យចូលឆ្នាំខ្មែរគេហៅថាថ្ងៃមហាសង្ក្រាន្ត។



ជាចុងក្រោយ ថ្ងៃសុក្រដែលជាថ្ងៃចូលឆ្នាំទីមួយបានមកដល់។
យ៉េកនិងខេទីនាំគ្នាជិះរ៉ឺម៉កកង់បីមកជាមួយគ្នា ឯលោកគ្រូសុខបានដើរមកជួបជុំគ្នានៅផ្ទះរតនានិងមករា។
ខេទីលាន់មាត់ « អូ! តុបតែងបានស្អាតខ្លាំងណាស់ថ្ងៃនេះ »។
លោកគ្រូសុខក៏ប្រាប់យ៉េកនិងខេទី ថាថ្ងៃទីមួយនៃបុណ្យចូលឆ្នាំខ្មែរគេហៅថា ថ្ងៃមហាសង្ក្រាន្ត។
« នេះជាថ្ងៃដែលយើងទទួលស្វាគមន៍ទេវតាឆ្នាំថ្មី។ ផ្លែឈើ ទានធូបនិងភ្លើងលំអទាំងនេះជារណ្ដាប់សម្រាប់ទទួលទេវតាឆ្នាំថ្មី ដើម្បីឱ្យទ្រង់ប្រោសប្រណីការពារផ្ទះនិងក្រុមគ្រួសារយើង។ បន្ទាប់មក យើងនឹងទៅវត្តដើម្បីប្រគេនចង្ហាន់ជូនលោកសង្ឃផងដែរ »។




នៅលើរ៉ឺម៉កកង់បី មករាបានសួរខេទី « តើអ្នកចេះសំពះថ្វាយបង្គំលោកសង្ឃឬទេ? »
ខេទីប្រាប់ « ខ្ញុំមិនចេះទេ »។
មករាក៏ដាក់ដៃផ្ទឹមគ្នា ហើយលើកដៃសំពះដល់ថ្ងាសឱនចុះឱនឡើងចំនួន៣ដង។
គាត់ប្រាប់ខេទី « នេះហើយជារបៀបសំពះលោកសង្ឃ។ ខ្ញុំទើបរៀនចេះពីសាលាមត្តេយ្យមក! »



ថ្ងៃបន្ទាប់ជាថ្ងៃសៅរ៍ យ៉េកក៏បានមកដឹកអ្នកទាំងអស់គ្នាទៅវត្តម្តងទៀត។ ខេទីសួរលោកគ្រូសុខ « ថ្ងៃនេះជាថ្ងៃអ្វី? » នេះជាថ្ងៃទីពីរនៃពិធីបុណ្យចូលឆ្នាំដែលឈ្មោះថា វិរៈវ័នបត។ ថ្ងៃនេះជាថ្ងៃដែលយើងរំលឹកដល់ដូនតាយើងដោយប្រគេនចង្ហាន់ដល់លោកសង្ឃនិងឱ្យទានដល់អ្នកក្រខ្សត់។

អង្គការរ៉ឺម៉កកង់បី
សម្រាប់កុមារ R4C



ក្រោយពីបានប្រគេនចង្ហាន់លោករួចរាល់ហើយ រតនានិងមករាបានទៅអង្គុយកាយខ្សាច់។
ខេទីឆ្ងល់ក៏សួរ « តើអ្នកទាំងពីរកំពុងលេងដីមែនហ្នឹង? »
មករាឆ្លើយវិញ « មិនមែនទេ! យើងកំពុងពូនខ្សាច់ដើម្បីដាក់លើវាលុកចេតិយជាភ្នំខ្សាច់នៅទីនេះ។
ដំបូង យើងពូនចេតិយនៅកណ្តាល ហើយបន្តពូនលើគ្រប់ចេតិយទាំងអស់ពីឆ្វេងទៅស្តាំ។
យើងធ្វើអីចឹងគឺដើម្បីបួងសួងដល់ដូនតាយើងនិងសុំឱ្យគ្រួសារយើងមានសុខភាពល្អផងដែរ »។





ថ្ងៃអាទិត្យជាថ្ងៃចុងក្រោយនៃពិធីបុណ្យចូលឆ្នាំដែលមានឈ្មោះថា វារៈឡើងស័ក។
នៅវត្ត គេនាំគ្នាយកទឹកទៅស្រង់ព្រះ។
រតនាប្រាប់ខេទី « ធ្វើអីចឹងគឺយើងលាងបាបដែលយើងបានសាងពីឆ្នាំមុន
ហើយវាក៏នាំសេចក្ដីសុខមកឱ្យយើងនៅឆ្នាំថ្មីនេះផងដែរ »។



អង្គការរ៉ឺម៉កកង់បី
សម្រាប់កុមារ R4C

ពេលទៅដល់ភូមិវិញ ដល់ពេលគេនាំគ្នាស្រង់ព្រះរស់ម្តង។
រតនានិងមករាក៏បានចូលជួយគេស្រង់ព្រះរស់នឹងគេផងដែរ។
រតនានិយាយ « ខ្ញុំសង្ឃឹមថាលោកតានឹងឱ្យដិបូន្នានល្អៗដល់ខ្ញុំដូចឆ្នាំមុនៗអីចឹង »។





ក្រោយពេលគេបានស្រង់ព្រះរស្ងួចរាល់អស់ហើយនោះ ពួកគេក៏ញ៉ាំបាយជុំគ្នា។
ក្រោយពីញ៉ាំចប់សព្វគ្រប់ហើយនោះ លោកគ្រូសុខក៏បានដើរលបៗទៅក្រោយបាត់...





« តើទាំងអស់គ្នារៀបចំខ្លួនហើយឬនៅ? » លោកគ្រូសុខនិយាយទាំងដៃមានកាន់ស្បោងខៀវធំមួយ។
« យេ៉! » ពួកក្មេងៗស្រែកហើយរត់ជុំវិញលោកគ្រូសុខ។
មករាស្រែកប្រាប់ឱ្យយ៉េកចូលទៅខាងប្រុស។ រតនាក៏ប្រាប់ឱ្យខេទីចូលជួយខាងស្រី។
យ៉េកឆ្ងល់ក៏សួរ « គេកំពុងធ្វើអីហ្នឹង? »
លោកគ្រូសុខក៏ឆ្លើយ « ដល់ពេលលេងល្បែងប្រជាប្រិយខ្មែរយើងហើយ! »



ដំបូង ពួកគាត់លេងល្បែងចោលឈូង



បោះអង្គុញ





និងស្វាដណ្ដើមស្លឹកឈើសិន។
ក្រុមខាងស្រីស្រែកហ៊ោកញ្ជ្រៀវ ដោយសារក្រុមខាងប្រុសៗចាញ់ ហើយត្រូវច្រៀងនិងរាំជាពិន័យ។



បន្ទាប់មកលោកគ្រូសុខបានប្រាប់ទាំងអស់គ្នាឱ្យអង្គុយជារង្វង់។
ម្នាក់ៗក៏ធ្វើតាមសំដីគាត់ ហើយពួកគេក៏ចាប់ផ្ដើមលេងល្បែងលាក់កន្សែង។
ក្មេងៗចូលចិត្តដេញចាប់យ៉េកនិងខេទីណាស់។




« បាទ! ដល់ពេលយើងលេងទាញព្រ័ត្រហើយ! »
« យ៉េ! » ម្នាក់ៗហក់ឡើងឈរ ហើយតម្រង់ជួរ។
« ១ ២ ៣ ចាប់ផ្តើម! » យ៉េកក៏ចូលជួរជាមួយក្រុមប្រុសៗ។

អង្គការរ៉ឺម៉កកង់បី
សម្រាប់កុមារ R4C



តែភ្លាមនោះ ក្រុមខាងស្រីៗក៏នាំគ្នាស្រែកថា « អយុត្តិធម៌ណាស់! យ៉េកមានកម្លាំងស្មើមនុស្សដប់នាក់ទៅហើយហ្នឹង! »
លោកគ្រូសុខក៏ដោះស្រាយ « មិនអីទេៗ! ម្ដងនេះ ពីរនាក់ខ្ញុំនិងយ៉េកនឹងទាញជាមួយអ្នកទាំងអស់គ្នាក៏បាន »។
« យ៉េ! » ក្មេងៗនាំគ្នាស្រែកសប្បាយរីករាយ។




យ៉េកក៏លាន់មាត់ « ពិធីបុណ្យចូលឆ្នាំខ្មែរពិតជាសប្បាយពិតមែន! រីករាយថ្ងៃបុណ្យចូលឆ្នាំថ្មីទាំងអស់គ្នា! »។
ក្មេងៗក៏ស្រែកតប « រីករាយថ្ងៃបុណ្យចូលឆ្នាំថ្មី! »។
ខេទីក៏ស្រែកសួរពីក្រោយ « រៀបចំខ្លួនហើយឬនៅទាំងអស់គ្នា? ១ ២ ៣ ចាប់ផ្ដើម! »៕